*Embassy of the United States of America*

## សាលាក្តីខ្មែរក្រហម និងតម្រូវការអោយមានយុត្តិធម៌
## សុន្ទរកថា របស់លោកឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ចូសេហ្វ មូស្សូមេលី
## នៅក្នុងកិច្ចប្រជុំជាមួយនឹងជនរងគ្រោះដោយរបបខ្មែរក្រហម
## ថ្ងៃទី២៨ មិនា ឆ្នាំ២០០៦

ឧក្រិដ្ឋកម្មមួយក្នុងចំនោមឧក្រិដ្ឋកម្មដ៏ធំបំផុតប្រចាំសតវត្សទី២០ បានកន្លងទៅដោយមិនមានការដាក់ទណ្ឌកម្មរហូតដល់៣០ឆ្នាំ។ ដូចដែលលោក លោកស្រីបានជ្រាបហើយ ក្នុងចន្លោះពីថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៨ មករា ១៩៧៩ គឺក្នុងរយៈពេលតែជិតបួនឆ្នាំប៉ុណ្ណោះ របបខ្មែរក្រហម បានធ្វើទារុណកម្ម បង្អត់អាហារ និង សំលាប់ ("កំទេច" គឺជាពាក្យដែលពួកគេចូលចិត្តប្រើ) ប្រជាជនកម្ពុជា អស់២.២ លាននាក់។ ចំនួននេះ ស្មើនឹងចន្លោះ ពីមួយភាគបួន ទៅមួយភាគបី នៃចំនួនប្រជាជនទាំងអស់។ គ្មាននរណាម្នាក់បានរួចខ្លួនពី "អ្នករំដោះប្រជាជន" ទាំងអស់នេះទេ។ បញ្ជីរាយនាមសត្រូវរបស់គេវែងណាស់ : ជនជាតិអ៊ីស្លាម ជនជាតិភាគតិចវៀតណាម ព្រះសង្ឃ អ្នកទីក្រុង អ្នកដែលមានសញ្ញាប័ត្រ អ្នកពាក់វ៉ែនតា ហើយជាពិសេស ពួកខ្មែរក្រហមខ្លួនឯងដែលត្រូវគេសង្ស័យថាក្បត់ផងដែរ។ ក្រុមទាំងនេះ ហើយនិងអ្នកដទៃជាច្រើនទៀត រួមមានភរិយា ស្វាមី និងកូន ត្រូវបានកំចាត់ទាំងឫស នៅក្នុងរបបប្រល័យពូជសាសន៍ដែលសាហាវបំផុតមិនធ្លាប់មានពីមុនមក។

ហេតុអ្វីបានជាខ្ញុំនិយាយថា "ជារបបប្រល័យពូជសាសន៍ដែលមិនធ្លាប់មាន" នៅពេលដែលពិភពលោក មានការប្រកួតប្រជែងយ៉ាងតឹងតែង ហើយដែលជួនកាល ហាក់ដូចជាបាត់បង់អស់នូវគុណធម៌ និងសេចក្តីអាណិតអាសូរចំពោះអ្នកដទៃដូច្នេះ? ពីព្រោះ នេះជារបបប្រល័យពូជសាសន៍តែមួយគត់ ដែលមិនបាននាំអ្នកដែលមានទោសចំពោះបទឧក្រិដ្ឋនេះ មកទទួលខុសត្រូវចំពោះមុខច្បាប់ឡើយ។ អ្នកដែលទទួលរងគ្រោះ គ្រួសាររបស់គេ និងសហគមន៍អន្តរជាតិ សុទ្ធតែបានទទួលនូវភាពយុត្តិធម៌ និងបានសងសឹកនៅក្នុងករណីណាមួយ តាមរយៈសាលាក្តី Nuremberg និងសវនាការថ្នាក់ជាតិ និងអន្តរជាតិក្រោយៗទៀត ដែលបានកាត់ទោសឃាតករសម្លាប់រង្គាល នៅបូស្នី ស៊ែរប៊ី លីបេរី អេចូពី និងរវ៉ាន់ដា។ ប៉ុន្តែប្រការនេះមិនបានកើតឡើងនៅប្រទេសកម្ពុជាទេ។

ថ្មីៗនេះ យើងបានឃើញមានការរីកចំរើនខ្លះ ក្នុងការបង្កើតសាលាក្តីខ្មែរក្រហម (KRT) ដោយមានការសហការជាមួយនឹងអង្គការសហប្រជាជាតិ (UN)។ ប៉ុន្តែយើងមានពេលវេលាកាន់តែតិចទៅៗ ដោយសារឃាតករទាំងនោះកាន់តែចាស់ និងបាត់បង់ទៅ ប៉ុន្តែការឈឺចាប់ និងរន្ធត់ដែលពួកគេបង្កឡើង មិនគួរនឹងបណ្តោយអោយបាត់បង់ទៅ មិនគួរនឹងអោយរលុបបាត់បានឡើយ។

តើវាមានប្រយោជន៍អ្វី? អ្នកខ្លះអាចនិយាយថា ការចំណាយថវិការដែលមានតិចតួច ទៅលើបទឧក្រិដ្ឋដែលមានចំណាស់៣០ឆ្នាំទៅហើយ នៅពេលដែលប្រទេសកម្ពុជាទទួលរងនូវបញ្ហាបន្ទាន់ផ្សេងទៀតជាច្រើននោះ ជា

រឿងមិនសក្តិសមមួយ ។ ខ្ញុំសង្ឃឹមថា ប្រជាជនកម្ពុជាភាគច្រើនមិនយល់ស្របនឹងការអះអាងនេះទេ។ ក្នុងប្រទេសកម្ពុជា អ្នកដែលបានប្រព្រឹត្តបទឧក្រិដ្ឋប្រល័យពូជសាសន៍ទាំងនោះ ភាគច្រើនរស់នៅយ៉ាងសុខសាន្ត មានសេរីភាព ថែមទាំងហ៊ឺហាទៀតផង ជាមួយនឹងជនរងគ្រោះដែលគេបានធ្វើបាប ។ មិនមានគ្រួសារណាមួយក្នុងប្រទេសកម្ពុជា ដែលមិនរងគ្រោះពីរបបប្រល័យពូជសាសន៍នោះឡើយ ។ អ្នករាល់គ្នាដែលមានជីវិតនៅថ្ងៃនេះ សុទ្ធតែមានឪពុក ម្តាយ បងប្អូន មីង និងពូ ដែលបានស្លាប់នៅក្នុងការសម្លាប់រង្គាលនោះ ។

ខ្មែរក្រហម បានប្រកាសថា គេនឹងនាំប្រទេសកម្ពុជាទៅកាន់ "ឆ្នាំសូន្យ" ។ គេបានរក្សាពាក្យសន្យារបស់គេបានយ៉ាងល្អ ហើយនៅពេលនេះ គឺ ៣០ឆ្នាំក្រោយមក ប្រទេសនេះនៅតែបាត់បង់ និងបាក់បែកនៅឡើយ ។ ការបែកបាក់របស់ប្រទេសកម្ពុជាមិនដោយសារតែនយោបាយ និងសេដ្ឋកិច្ចប៉ុណ្ណោះទេ ។ វាជាការបែកបាក់នូវប្រព័ន្ធច្បាប់ ផ្លូវចិត្ត និងស្មារតី ។ រាល់កំហុសឆ្គងទាំងឡាយក្នុងសង្គមកម្ពុជាបច្ចុប្បន្ន រួមមានការជួញដូរមនុស្ស ការជួញដូរថ្នាំញៀន ការលួចប្លន់ធនធានធម្មជាតិ និងវប្បធម៌ និងអំពើពុករលួយដែលជ្រៀតចូលទៅគ្រប់ស្រទាប់រដ្ឋាភិបាល ទាំងអស់នេះសុទ្ធតែត្រូវបានធ្វើអោយកាន់តែធ្ងន់ធ្ងរឡើង ដោយសារការបរាជ័យរបស់សហគមន៍អន្តរជាតិ ក្នុងការនាំយកអ្នកដឹកនាំខ្មែរក្រហមមកកាត់ទោសចំពោះមុខច្បាប់ ។

វប្បធម៌និទណ្ឌភាព ដែលយើងឃើញនៅក្នុងសង្គមកម្ពុជាសព្វថ្ងៃ បានចាក់ឫសយ៉ាងជ្រៅ ទៅក្នុងជំនឿដែលមិនអាចប្រកែកបានរបស់ប្រជាជនកម្ពុជា ដែលជឿថា គ្មានបទល្មើសណាដែលធំ រហូតដល់ថ្នាក់ចាំបាច់ត្រូវតែទទួលទណ្ឌកម្មនោះទេ ហើយថា ទោះជាប្រជាជនកម្ពុជាណាម្នាក់ធ្វើអ្វីមួយក៏ដោយ ក៏មិនមានបញ្ហាអ្វីដែរ ពីព្រោះវាមិនអាចនឹងមានអ្វី ដែលអាក្រក់ជាងអ្វីដែលពួកខ្មែរក្រហមធ្វើនោះទេ ហើយគេបានរួចខ្លួនទៀតផង ។ សាលាក្តីខ្មែរក្រហមជាជំហានចាំបាច់ដំបូង ដើម្បីព្យាបាលរបួសដែលមានចំណាស់៣ទសវត្ស ហើយដែលនៅក្លាយ មិនទាន់ជាសះនៅឡើយ ។ ការរាំងស្ទះដល់ការរីកចំរើន និងកំនែទំរង់របស់ប្រទេសកម្ពុជា នឹងនៅតែមាន លុះត្រាណាតែយុត្តិធម៌ក្នុងកំរិតណាមួយត្រូវបានគេរកឃើញ ។ អ្នកទាំងឡាយដែលបានស្លាប់ និងទទួលរងគ្រោះ : មរណភាពរបស់ពួកគេ និងការឈឺចាប់របស់ពួកគេ ត្រូវតែបានគេទទួលស្គាល់ថាជាការពិត និងត្រូវតែបានគេគោរពបូជា ។ ជនរងគ្រោះនៃរបបខ្មែរក្រហម សមនឹងទទួលបាននូវភាពយុត្តិធម៌ ។ ជនរងគ្រោះនៃរបបប្រល័យពូជសាសន៍ទាមទារអោយមានយុត្តិធម៌ ។ វាជាសិទ្ធិរបស់ពួកគេក្នុងការទទួលបានយុត្តិធម៌ ហើយវាជាកាតព្វកិច្ចរបស់យើងក្នុងការធានាអោយមានយុត្តិធម៌ ។